# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០១៣

## ជប៉ុនផ្តល់១៩២,៤៧៣ដុល្លារអាមេរិកសម្រាប់គម្រោងផ្នែកសុខាភិបាលចំនួន២



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឥតសំណងសម្រាប់ គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ(ជំនួយ គូសាណូណិ) រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន១៩២,៤៧៣ ដុល្លារអាមេរិកដល់ស្ថាប័នទទួលជំនួយចំនួន២។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខា ថ្ងៃនេះដោយឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង តំណាងស្ថាប័នទទួលជំនួយនិមួយៗ ដើម្បីអនុវត្តគម្រោងដូចតទៅះ



១. គម្រោងសាងសង់អគារព្យាបាលជំងឺទូទៅក្នុងមន្ទីរពេទ្យបង្អែកជើងព្រៃ ខេត្តកំពង់ចាម(១១៦,៩៥០ដុល្លារអាមេរិក)

ស្ថាប័នទទួលជំនួយះ ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិជើងព្រៃ

ដើម្បីឆ្លើយតបទៅនឹងបញ្ហាកង្វះបន្ទប់មន្ទីរពេទ្យនិងសម្ភារៈបរិក្ខារពេទ្យ ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិជើងព្រៃនឹងអនុវត្តគម្រោងសាងសង់អគារជំងឺទូទៅមួយដែលមានកម្ពស់២ជាន់ រួមមានបន្ទប់សម្រាកព្យាបាលចំនួន៣បន្ទប់ បន្ទប់ ICUមួយ និងបន្ទប់ប្រចាំការមួយ ព្រមទាំងបំពាក់សម្ភារៈបរិក្ខារពេទ្យដែលចាំបាច់ក្នុងមន្ទីរពេទ្យបង្អែកជើងព្រៃ។ គម្រោងនេះនឹងធ្វើឲ្យប្រជាជនប្រមាណ២០០,០០០នាក់ដែលរស់នៅក្នុងស្រុកជើងព្រៃ និងស្រុកក្បែរខាងក្នុងខេត្តកំពង់ចាមអាចទទួលបានអត្ថប្រយោជន៍ពីសេវាសុខាភិបាលកាន់តែប្រសើរឡើង ដោយសារមន្ទីរពេទ្យនឹងមានបន្ទប់ICUធំទូលាយសម្រាប់ធ្វើការវះកាត់សង្គ្រោះបន្ទាន់ ហើយអ្នកជំងឺអាចស្នាក់នៅព្យាបាលក្នុងមន្ទីរពេទ្យប្រកបដោយសុវត្ថិភាព និងការយកចិត្តទុកដាក់ខ្ពស់។



២. គម្រោងសាងសង់មណ្ឌលសុខភាពយុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប (៧៥,៥២៣ដុល្លារអាមេរិក)_

ស្ថាប័នទទួលជំនួយះ អង្គការភ្លែនអន្តរជាតិ - កម្ពុជា

ដើម្បីធ្វើឲ្យប្រជាជនក្នុងឃុំយុនរាម ស្រុកបន្ទាយស្រីអាចទទួលបានសេវាសុខាភិបាលកាន់តែប្រសើរ អង្គការភ្លែនអន្តរជាតិ-កម្ពុជានឹងសាងសង់មណ្ឌលសុខភាពមួយនៅក្នុងឃុំនេះ។ យើងរំពឹងថា ប្រជាជនប្រមាណ៦,៤០០នាក់នៃឃុំយុនរាម និងឃុំក្បែខាងដែលធ្លាប់តែមានការលំបាកក្នុងការធ្វើដំណើរទៅកាន់មណ្ឌលសុខភាពដែលនៅឆ្ងាយពីឃុំរបស់ពួកគេ អាចទទួលបានសេវាសុខភាពមូលដ្ឋាន ជាពិសេសសេវាគាំពារមាតា និងទារក។ គោលបំណងសំខាន់នៃគម្រោងនេះ គឺដើម្បីកាត់បន្ថយអត្រាមរណៈមាតា និងទារកដែលកំពុងមានកម្រិតខ្ពស់ក្នុងតំបន់។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណិ) របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍

និងស្ថាបនាប្រទេសឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជិវិត និងសេចក្ដីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១រដ្ឋាភិបាលជប៉ុនបានផ្ដល់ថវិកាជាង ៥០.៣លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន ៥០៣គម្រោងនៅទូទាំងប្រទេស។



---


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*